クメール語版（カンボジア語）

# របៀបចោលសំរាម និងធនធាន

## សៀវភៅណែនាំសំរាប់ប្រើប្រាស់តាមផ្ទះ





## គោលការណ៍4យ៉ាងក្នុងការចោលសំរាម

### 1 ចូរយើងបែងចែកសំរាម

សូមបែងចែកឱ្យបានត្រឹមត្រូវ ដើម្បីប្រើប្រាស់ធនធានយ៉ាងមានប្រសិទ្ធភាព។
**ជាពិសេស មានប្រភេទក្រដាសនៅលាយឡំយ៉ាងច្រើន**
**ហើយត្រូវបានដុតចោលទទេៗ។**




### 2 ចូរយើងគោរពពេលវេលា

សូមដាក់សំរាមនៅកន្លែងប្រមូលសំរាម **ចន្លោះពីព្រឹកព្រលឹមដល់ម៉ោង8**
**និង30នាទី** នៅថ្ងៃប្រមូលសំរាមដែលបានកំណត់។




### 3 ចូរយើងប្រកាន់ខ្ជាប់ថ្ងៃប្រមូលសំរាម

**សូមដាក់សំរាមនៅថ្ងៃដែលបានកំណត់។**
ថ្ងៃប្រមូលសំរាមខុសគ្នាតាមប្លុកប្រមូលសំរាម។
*វានឹងជាការរំខានដល់អ្នកជិតខាង។



### 4 ចំពោះកន្លែងប្រមូលសំរាមដែលត្រូវបានកំណត់

**កន្លែងប្រមូលសំរាមត្រូវប្រើប្រាស់រួមគ្នា**
**ហើយអ្នកទាំងអស់គ្នាក្នុងតំបន់ជាអ្នកគ្រប់គ្រងរក្សា។**
សូមប្រើប្រាស់ដោយប្រកាន់ខ្ជាប់បែបបទ។



# កាលវិភាគការប្រមូល

■ ត្រូវដាក់នៅកន្លែងប្រមូលសំរាមដែលត្រូវបានកំណត់ នៅត្រឹមម៉ោង៨:៣០ព្រឹក នៅថ្ងៃកំណត់ប្រមូល ។

■ ថ្ងៃសំរាកបុណ្យ ក៏ប្រមូលដែរ (លើកលែងតែចុងឆ្នាំ និងដើមឆ្នាំ) ។

| តំបន់ស្នាក់នៅ | Hanbara / Tashiro | | | | | | |
|---|---|---|---|---|---|---|---|
| តំបន់ប្រមូល | ថ្ងៃច័ន្ទ | ថ្ងៃអង្គារ | ថ្ងៃពុធ | ថ្ងៃព្រហស្បតិ៍ | ថ្ងៃសុក្រ | ថ្ងៃសៅរ៍ | ថ្ងៃអាទិត្យ |
| Hanbara Tashiro | សំរាមសំរាប់ដុត | ធនធាន A (២សប្តាហ៍ម្តង)<br>ធនធាន B (២សប្តាហ៍ម្តង) | ធនធាន C (រៀងរាល់សប្តាហ៍) សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក<br>ធនធាន C (២សប្តាហ៍ម្តង) មែកឈើដែលកាត់ចោល | សំរាមសំរាប់ដុត | គ្មានការប្រមូលទេ | គ្មានការប្រមូលទេ | |

ធនធាន A ដប, ប្រភេទក្រដាស, កញ្ចប់ក្រដាស, សំរាមដុតមិនបាន, ថ្មពិល, ស្នោ ធនធាន B កំប៉ុង, ដបប្លាស្ទិក, សំលៀកបំពាក់ចាស់ៗ

| តំបន់ស្នាក់នៅ | Kasugadai, មួយផ្នែករបស់ Nakatsu (Otsuka, Mutsukura (Uedan), Kamikumasaka (តំបន់ Sugawara)) | | | | | | |
|---|---|---|---|---|---|---|---|
| តំបន់ប្រមូល | ថ្ងៃច័ន្ទ | ថ្ងៃអង្គារ | ថ្ងៃពុធ | ថ្ងៃព្រហស្បតិ៍ | ថ្ងៃសុក្រ | ថ្ងៃសៅរ៍ | ថ្ងៃអាទិត្យ |
| Kasugadai | សំរាមសំរាប់ដុត | គ្មានការប្រមូលទេ | ធនធាន C (រៀងរាល់សប្តាហ៍) សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក<br>ធនធាន C (២សប្តាហ៍ម្តង) មែកឈើដែលកាត់ចោល | សំរាមសំរាប់ដុត | ធនធាន A (២សប្តាហ៍ម្តង)<br>ធនធាន B (២សប្តាហ៍ម្តង) | គ្មានការប្រមូលទេ | |

ធនធាន A ដប, ប្រភេទក្រដាស, កញ្ចប់ក្រដាស, សំរាមដុតមិនបាន, ថ្មពិល, ស្នោ ធនធាន B កំប៉ុង, ដបប្លាស្ទិក, សំលៀកបំពាក់ចាស់ៗ

| តំបន់ស្នាក់នៅ | Sumida, Mimase, ផ្នែកមួយនៃ Nakatsu (Shitamutsukura)<br>ចាប់ពីផ្លូវខេត្តលេខ ៦៥ (ផ្លូវខេត្តខ្សែ Atsugi Aikawa Tsukui) ដល់ខាងតំបន់ឧស្សាហកម្ម Nairiku | | | | | | |
|---|---|---|---|---|---|---|---|
| តំបន់ប្រមូល | ថ្ងៃច័ន្ទ | ថ្ងៃអង្គារ | ថ្ងៃពុធ | ថ្ងៃព្រហស្បតិ៍ | ថ្ងៃសុក្រ | ថ្ងៃសៅរ៍ | ថ្ងៃអាទិត្យ |
| Takamine Nakatsu ① | ធនធាន A (២សប្តាហ៍ម្តង)<br>ធនធាន B (២សប្តាហ៍ម្តង) | សំរាមសំរាប់ដុត | ធនធាន C (រៀងរាល់សប្តាហ៍) សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក<br>ធនធាន C (២សប្តាហ៍ម្តង) មែកឈើដែលកាត់ចោល | គ្មានការប្រមូលទេ | សំរាមសំរាប់ដុត | គ្មានការប្រមូលទេ | |

ធនធាន A ដប, ប្រភេទក្រដាស, កញ្ចប់ក្រដាស, សំរាមដុតមិនបាន, ថ្មពិល, ស្នោ ធនធាន B កំប៉ុង, ដបប្លាស្ទិក, សំលៀកបំពាក់ចាស់ៗ

- មិនត្រូវអនុញ្ញាតឱ្យដាក់នៅទីតាំងក្រៅពីកន្លែងកំណត់ រឺដាក់មួយយប់មុនពេលឡើយ ។
- មិនត្រូវអនុញ្ញាតឱ្យដាក់នៅថ្ងៃផ្សេងក្រៅពីថ្ងៃកំណត់ រឺនៅក្រោយពេលបានប្រមូលរួចហើយឡើយ ។
- ចំពោះសំរាម រឺធនធានដែលចេញពីការិយាល័យ ហាងធំៗ ហាងរបស់អាជីវករ ភោជនីយដ្ឋានជាដើម មិនត្រូវដាក់នៅកន្លែងប្រមូលសំរាមចេញពីផ្ទះបានឡើយ ។

| តំបន់ស្នាក់នៅ | ចាប់ពីផ្លូវខេត្តលេខ ៦៥ (ផ្លូវខេត្តខ្សែ Atsugi Aikawa Tsukui) ដល់ខាងស្ទឹង Nakatsu | | | | | | |
|---|---|---|---|---|---|---|---|
| **តំបន់ប្រមូល** | **ថ្ងៃច័ន្ទ** | **ថ្ងៃអង្គារ** | **ថ្ងៃពុធ** | **ថ្ងៃព្រហស្បតិ៍** | **ថ្ងៃសុក្រ** | **ថ្ងៃសៅរ៍** | **ថ្ងៃអាទិត្យ** |
| **Nakatsu ②** | គ្មានការប្រមូលទេ | សំរាមសំរាប់ដុត | ធនធាន C (រៀងរាល់សប្តាហ៍) សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក<br>ធនធាន C (២សប្តាហ៍ម្តង) មែកឈើដែលកាត់ចោល | ធនធាន A (២សប្តាហ៍ម្តង)<br>ធនធាន B (២សប្តាហ៍ម្តង) | សំរាមសំរាប់ដុត | គ្មានការប្រមូលទេ | |

ធនធាន A ដប, ប្រភេទក្រដាស, កញ្ចប់ក្រដាស, សំរាមដុតមិនបាន, ថ្មពិល, ស្ពោ ធនធាន B កំប៉ុង, ដបប្លាស្ទិក, សំលៀកបំពាក់ចាស់ៗ

# ផែនទីប្លុកប្រមូលសំរាម

**※ចំពោះការយកមកដល់ Bika Plant**

**ច័ន្ទ ~ សុក្រ** 9:00 ~ 11:30, 13:00 ~ 16:30
**សៅរ៍** 9:00 ~ 11:30




| ប្លុកប្រមូលសំរាម | តំបន់ប្រមូលសំរាម |
|---|---|
| Hanbara | Hanbara |
| Tashiro | Tashiro |
| Kasugadai | Kasugadai, ផ្នែកមួយនៃ Nakatsu (Otsuka, Mutsukura (Uedan), Kamikumasaka (តំបន់ Sugawara)) |
| Takamine | Sumida, Mimase, ផ្នែកមួយនៃ Nakatsu (Shitamutsukura) |
| Nakatsu ① | ចាប់ពីផ្លូវខេត្តលេខ ៦៥ (ផ្លូវខេត្តខ្សែ Atsugi Aikawa Tsukui) ដល់ខាងតំបន់ឧស្សាហកម្ម Nairiku |
| Nakatsu ② | ចាប់ពីផ្លូវខេត្តលេខ ៦៥ (ផ្លូវខេត្តខ្សែ Atsugi Aikawa Tsukui) ដល់ខាងស្ទឹង Nakatsu |

# សំរាមសំរាប់ដុត



※ ដាក់នៅក្នុងថុងពណ៌ថ្លា រឺ ថ្លាពាក់កណ្តាល
ហើយរឹតអោយជិតនៅមាត់ថង់ ។

■ សំរាមផ្ទះបាយ

※ សំរាមផ្ទះបាយនេះ
ត្រូវច្របាច់រឹតឱ្យអស់ទឹក ។
ការច្របាច់រឹតឱ្យអស់ទឹកនេះ
អាចកាត់បន្ថយទំងន់បាន ១០% ។



■ សំរាមក្រដាសកខ្វក់ ដូចជាក្រដាស ជូតដែលបានប្រើប្រាស់ជាដើម



■ សំបកខ្យង ពងមាន់ជាដើម



■ ផលិតផលស្បែកជាដើម



■ ធុង រឺប្រដាប់ដាក់ទឹក ធ្វើពីប្លាស្ទិក



■ កាសែតវីឌេអូ DVD កាសែតចំរៀង CD



■ សំភារៈសិក្សា ឬការិយាល័យ ដូចជាប៊ិច បន្ទាត់ជាដើម



# ធនធាន A

## ដប

■ ដបស្រាបៀរ

■ ដបធំពណ៌ត្នោត រឺ បៃតង

■ ដបភេសជ្ជៈ ដបគ្រឿងទេស ដបគ្រឿងសំអាង ដបស្រាវីស្គីជាដើម

※ លាងដោយទឹក រួចហើយដាក់នៅក្នុងថុងពណ៌ថ្លា រឺថ្លាពាក់កណ្តាល ។



## សំរាមដុតមិនបាន

■ នាឡិកា



■ ទំពួកព្យួរខោអាវធ្វើពីសរសៃដែក



■ ឆ័ត្រ



■ ឆ្នាំងដាំបាយ



※ ដាក់នៅក្នុងថុងពណ៌ថ្លា រឺថ្លាពាក់កណ្តាល ។
※ សំរាមធំៗ មិនចាំបាច់ដាក់ចូលក្នុងថុងទេ
ក៏ប៉ុន្តែក្នុងករណីមានឆ័ត្រចំនួនច្រើនត្រូវយកខ្សែចង ។

■ ចាន



■ កែវ



■ កំទិចអំបែងកញ្ចក់



※ ដាក់នៅក្នុងថុងពណ៌ថ្លា រឺថ្លាពាក់កណ្តាល ។ ក៏ប៉ុន្តែប្រភេទកញ្ចក់ដែលបែក
មុននឹងដាក់ចូលក្នុងថុង ត្រូវសរសេរ " **キケン** " នៅលើក្រដាសខ្ចប់ ។

■ ដែកកេស



※ ប្រើអោយអស់ ហើយដាក់នៅក្នុងថុងពណ៌ថ្លា
រឺថ្លាពាក់កណ្តាល ។ មុននឹងដាក់ចូលក្នុងថុង
សរសេរ " **ライター** " ។

■ ប្រដាប់វាស់កំដៅសីតុណ្ហភាព កំដៅខ្លួន



※ ដាក់នៅក្នុងថុងពណ៌ថ្លា រឺថ្លាពាក់កណ្តាល ។
មុននឹងដាក់ចូលក្នុងថុង ត្រូវសរសេរ
" **オンドケイ・タイオンケイ** " ។

■ អំពូលភ្លើង



※ ដាក់នៅក្នុងថុងពណ៌ថ្លា រឺ ថ្លាពាក់កណ្តាល រឺសំបក
ប្រអប់នៃអំពូលភ្លើងនោះ ។ ចំពោះវត្ថុដែលខូច
មុននឹងដាក់ចូលក្នុងថុង ត្រូវសរសេរ " **キケン** " ។

# ប្រភេទក្រដាស

## ■ ទស្សនាវដ្ដី សៀវភៅ (ទស្សនាវដ្ដីប្រចាំសប្ដាហ៍ ទស្សនាវដ្ដីប្រចាំខែ សៀវភៅមេរៀន សៀវភៅសរសេរ ឯកសារជាដើម)






※ យកខ្សែចងឱ្យតឹងទើបដាក់ ។

## ■ កាសែត (រួមទាំងក្រដាសផ្សាយពាណិជ្ជកម្ម)





※ យកខ្សែចងទាំងកាសែត ទាំងក្រដាស ផ្សាយពាណិជ្ជកម្មទើបដាក់ ។

## ■ ឡាម






※ បត់អោយតូច ហើយយក ខ្សែចងឱ្យតឹងទើបដាក់ ។

## ■ ទស្សនាវដ្ដីកាសែតចាស់ៗ

❍ ប្រអប់ក្រដាសខ្ចប់នំ



❍ ក្រដាសវេចខ្ចប់



❍ កញ្ចប់បារី



❍ កាតប៉ុស្ដាល់ រឺសំបុត្រ



❍ ស្នូលក្រដាសអនាម័យ ក្រដាសបួស្ទិក



❍ ប្រអប់ក្រដាសអនាម័យ

※ ដកចេញនូវផ្នែកប្លាស្ទិក ហើយដាក់នៅក្នុងប្រភេទ "សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក" ។






※ ដកចេញនូវផ្នែកប្លាស្ទិក ហើយដាក់នៅក្នុងប្រភេទ "វេចខ្ចប់ប្រអប់ប្លាស្ទិក" ។

※ មិនត្រូវលាយឡំគ្នា នៅក្រដាស ដែលកាត់ដោយម៉ាស៊ីនកាត់ក្រដាស ។

## ■ ក្រដាសដែលកាត់ដោយម៉ាស៊ីនកាត់ក្រដាស

※ ដាក់នៅក្នុងធុងពណ៌ថ្លា រឺ ថ្លាពាក់កណ្ដាល ។



# ប្រអប់ធ្វើពីក្រដាស (ប្រអប់ទឹកដោះគោជាដើម)

※ ត្រូវលាងប្រអប់នោះ ហើយដាក់ឱ្យស្រក់ទឹកចេញអស់ ហើយច្របាច់វាឱ្យតូច រួចយកខ្សែចងឱ្យតឹងទើបដាក់ចូលក្នុងធុង ។

※ ចំពោះប្រអប់ដែលមានស្បែកអាលុយមីញ៉ូមត្រូវដាក់នៅ "សំរាមសំរាប់ដុត" ។



**វត្ថុដែលមិនអាចធ្វើជាធនធានបាន ・・・ ដាក់នៅក្នុង "សំរាមសំរាប់ដុត"**

ក្រដាសកែច្នៃការពារទទឹក (កែវក្រដាស កែវ Yogurt ប្រអប់ក្រដាសសំរាប់ Natto ជាដើម), ក្រដាសម៉ាស៊ីនលេចអក្សរដោយកំដៅ (ក្រដាស Receipt, ក្រដាស FAX ជាដើម), រូបថត, ក្រដាសប្រេង, ក្រដាសកាបូន, ក្រដាសអស់កាបូន (ប័ណ្ណថតចំលងរបស់កញ្ចប់បញ្ញើជាដើម) ជាដើម ។

# ថ្មពិល

※ ដាក់នៅក្នុងធុងពណ៌ថ្លា រឺ ថ្លាពាក់កណ្ដាល ។ មុននឹងដាក់ ត្រូវសរសេរ "**カンデンチ**" ។

※ ចំពោះថ្មពិលសាក រឺថ្មពិលរាងមូលតូចៗ ត្រូវដាក់នៅប្រអប់ប្រមូលនៅតាមហាង ។



# ស្នោ

※ ដាក់គរៗលើគ្នា ដើម្បីកុំឱ្យខ្យល់បក់ប៉ើង ។

※ វត្ថុណាដែលមានសញ្ញា プラ ត្រូវដាក់នៅតាម "សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក" ។



# ធនធាន B

កំប៉ុង
អាលុយមីញ៉ូម

កំប៉ុងដែក

## កំប៉ុង

■ កំប៉ុង Nori, កំប៉ុងម្ហូប, កំប៉ុងស្លឹកតែ



■ កំប៉ុង Spray

※ ប្រើអោយអស់ហើយ បើកប្រហោង ។



■ កំប៉ុងអាលុយមីញ៉ូម, កំប៉ុងដែក

※ លាងហើយដាក់ ។

※ ចំពោះកំប៉ុងអាលុយមីញ៉ូម ត្រូវជាន់ឱ្យកំប៉ិតសិន ទើបដាក់ ។





## ដបប្លាស្ទិក

※ ដកក្រដាសប្លាស្ទិក និងគំរបចេញ ហើយលាងដោយទឹក ។

※ ចំពោះក្រដាសប្លាស្ទិក និងគំរប ត្រូវដាក់នៅក្នុងប្រភេទ "សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក" ។

ចំពោះតែវត្ថុ ដែលមានសញ្ញា

PET







កំទេចកំទី



※ ដាក់នៅក្នុងថង់ពណ៌ថ្លា រឺថ្លាពាក់កណ្តាល ។

## សំលៀកបំពាក់ចាស់ៗ

※ ចំពោះខោអាវណាដែលប្រឡាក់ច្រើន ត្រូវដាក់នៅក្នុងប្រភេទ "សំរាមសំរាប់ដុត" ។

※ បោក ហើយសំងួតរួចហើយ ដាក់នៅក្នុងថង់ពណ៌ថ្លា រឺ ថ្លាពាក់កណ្តាល ដោយទុកឡេវជាដើម ហើយដាក់ ។

■ ប្រភេទខោអាវ



■ ប្រភេទអាវធំ





**ខោអាវដែលមានសំឡី (អាវស្តើជាដើម) រឺស្បែកជើងក្នុងផ្ទះ Slippers ត្រូវដាក់នៅក្នុងប្រភេទ "សំរាមសំរាប់ដុត" ។**

**ចំពោះកំរាល រឺភួយជាដើម ត្រូវដាក់នៅក្នុងប្រភេទ "សំរាមធំ" ។**

## ប្រេងឆាដែលបានប្រើប្រាស់រួចហើយ

**※ ត្រូវយកមកដាក់នៅ Bika Plant (ពុំមានសេវាកម្មប្រមូលទេ ទើបមិនត្រូវដាក់នៅកន្លែងប្រមូលសំរាមឡើយ) ។**



※ ចំពោះប្រេងឆាដែលបានប្រើប្រាស់រួចហើយនេះ មានកំដៅក្តៅ និងមានគ្រោះថ្នាក់ ទើបត្រូវធ្វើអោយត្រជាក់សិនទើបចាក់ចែង ។



※ ដាក់នៅក្នុងដបទឹកសុទ្ធដែលដកក្រដាសប្លាស្ទិចរួចហើយ ។

※ កុំអោយមានកាកសំណល់លាយចូល ។




※ ចំពោះប្រេងឆាដែលពុំទាន់បើក ត្រូវយកមក Bika Plant ផ្ទាល់ ។

- **ចំពោះប្រេងធ្វូបប្រភេទសត្វ ដូចជា Butter រឺ Lard ប្រេងកាត ប្រេងម៉ាស៊ូត ប្រេងម៉ាស៊ីនជាដើម មិនត្រូវចូលក្នុងប្រភេទសំរាមនេះទេ ។**
- **ក្នុងករណីមិនអាចយកមក Bika Plant ទេនោះ ត្រូវបង្កកដោយថ្នាំ រឺបឺតដោយក្រដាសជាដើម ហើយដាក់នៅក្នុងប្រភេទ "សំរាមសំរាប់ដុត" ។**

# ធុងធាន C

ចំពោះតែមានសញ្ញា

## សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក

■ ថាសដាក់ម្ហូបដែលធ្វើពីស្នោ



■ ក្រដាសប្លាស្ទិក រឺគំរបដបទឹកសុទ្ធ




■ ថង់ម្ហូបអាហារ




■ ដបសាប៊ូកក់សក់ រឺសាប៊ូលាងចានជាដើម



■ ប្រអប់នំ មីកំប៉ុង បាយកញ្ចប់ជាដើម




■ ប្រអប់ពងមាន់



■ ក្រដាសហ៊ុំលខាងក្រៅរបស់ប្រអប់បារី ប្រអប់ក្រដាសជូតជាដើម



■ ស្នោ ឬក្រដាសការពារការប៉ះទង្គិចធ្វើពីស្នោ ដែលត្រូវប្រើប្រាស់សំរាប់វេចខ្ចប់គ្រឿងអេឡិចត្រូនិចជាដើម



### ចំពោះសំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក ត្រូវដាក់នៅក្នុងថង់មួយ

※ ប្រសិនបើមានថង់ច្រើនដាក់ជាមួយគ្នា នាំអោយពិបាកធ្វើការបែងចែក ។ សូមដាក់នៅក្នុងថង់តែមួយ ។



### នៅពេលដាក់ ត្រូវយកកាកសំណល់ចេញ

※ ត្រូវយកកាកសំណល់ចេញ ( ចំពោះប្រភេទបំពង់ ត្រូវហែកចេញ) ។ ក៏ប៉ុន្តែក្នុងករណីមិនអាចយកកាកសំណល់ចេញបានទេនោះ ត្រូវដាក់នៅក្នុងប្រភេទ "សំរាមសំរាប់ដុត" វិញ ។



### វិធីដាក់សំបកវេចខ្ចប់ជាប្រអប់ធ្វើពីប្លាស្ទិក



※ ចំពោះផ្ទៃខាងក្នុងនៃប្រអប់ ( ប្រភេទវេចខ្ចប់) ត្រូវប្រើប្រាស់អោយអស់ ។



※ ក្នុងករណីនៅមានកាកសំណល់នៅលើប្រអប់ ត្រូវជូត រឺលាងចេញដោយប្រើប្រាស់ទឹកដែលនៅសល់ពីការលាងចាន ។



※ ដាក់នៅថ្ងៃកំណត់ ដោយដាក់នៅក្នុងធុងពណ៌ថ្លា រឺថ្លាពាក់កណ្តាល ។

## មែកឈើដែលកាត់ចោល

■ មែកឈើដែលកាត់ចោល, ស្លឹកឈើជ្រុះ ស្លឹកនានា ។





※ ចំពោះទំហំអង្កត់ផ្ចិតរបស់មែក មិនត្រូវឱ្យលើសពី 5cm ហើយកាត់អោយស្មើៗគ្នាប្រហែល 50cm ទើបចងជាបាច់ដែលមានទំហំអង្កត់ផ្ចិតក្រោម 25cm ។



※ ចំពោះមែកតូចៗ ស្លឹកកាត់ ស្លឹកជ្រុះ ត្រូវប្រមូល ហើយដាក់នៅក្នុងធុងពណ៌ថ្លា រឺ ថ្លាពាក់កណ្តាល ។

# ចំពោះ “វត្ថុដែលត្រូវប្រើប្រាស់ឡើងវិញដោយសហគ្រាសផលិតកម្ម” រឺ “សំរាមធំ” មិនអាចយកទៅដាក់នៅកន្លែងប្រមូលសំរាមបានឡើយ (គិតលុយ) ។

## ឧទាហរណ៍របស់ “វត្ថុដែលត្រូវប្រើប្រាស់ឡើងវិញដោយសហគ្រាសផលិតកម្ម”

■ ម៉ាស៊ីនត្រជាក់ (រួមទាំងម៉ាស៊ីនដាក់នៅខាងក្រៅ)



■ ទូរទស្សន៍ (Cathode-ray tube type, Liquid crystal type, Plasma type)



■ ទូទឹកកក



■ ម៉ាស៊ីនបោកខោអាវ



■ ម៉ាស៊ីនសំងួតខោអាវ



## ឧទាហរណ៍ “សំរាមធំ”

■ តុ



■ ទូដាក់ខោអាវ



■ ភួយ (ភួយមួយត្រូវចាត់ទុកថារបស់មួយ)



■ កំរាលបន្ទប់



■ កង់



○ **អ្វីដែលហៅថា “សំរាមធំ” គឺវត្ថុដែលមានប្រវែងមួយផ្នែងៗលើសពី 50cm ។**

○ **វិធីដាក់សំរាម “វត្ថុដែលត្រូវប្រើប្រាស់ឡើងវិញដោយសហគ្រាសផលិតកម្ម” រឺ “សំរាមធំ”**

យកមក Bika Plant ផ្ទាល់ រឺសុំប្រមូលដោយឡែកតាមទូរស័ព្ទ ។

※ ប្រភេទសំរាមខ្លះ មិនអាចចាត់ចែងបានដោយឃុំ ពេលនោះ សូមសួរសំណួរនៅឯ Bika Plant ។

○ **ការយកមកសំរាម និងធនធាន**

| | |
|---|---|
| **កន្លែងយកមក** | **Aikawa-machi Bika Plant** 1656-2, Mimase, Aikawa-machi ទូរស័ព្ទ 046-281-2258 រឺ 046-281-2811 |
| **ថ្ងៃអនុញ្ញាតយកមក** | ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ (វៀរលែងថ្ងៃសៅរ៍, ថ្ងៃបុណ្យជាតិ, ចុងឆ្នាំ ដើមឆ្នាំគឺត្រូវសំរាក) |
| **ម៉ោងទទួល** | ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ 9:00~11:30, 13:00~16:30, ថ្ងៃសៅរ៍ 9:00 ~ 11:30 |
| **ប្រភេទ** | សំរាមសំរាប់ដុត, ធនធាន A-B-C, ប្រេងឆាដែលបានប្រើប្រាស់, វត្ថុដែលត្រូវប្រើប្រាស់ឡើងវិញដោយសហគ្រាសផលិតកម្ម រឺ សំរាមធំ គឺ “ត្រូវគិតលុយ” |
| **កំណត់សំគាល់** | ・ក្នុងពេលដែលយកវត្ថុដែលត្រូវប្រើប្រាស់ឡើងវិញដោយសហគ្រាសផលិតកម្មត្រូវទិញ “ប័ណ្ណប្រើប្រាស់ឡើងវិញនូវគ្រឿងអេឡិចត្រូនិច” នៅតាមប៉ុស្តិ៍ប្រៃសនីយ៍ទុកជាមុន ។<br>・ការយកសំរាមបរិមាណធំ ដោយគ្មានផែនការ សូមសាកសួរទៅ Bika Plant ទុកជាមុន ។<br>・សូមបង្ហាញអត្តសញ្ញាណប័ណ្ណដែលអាចបញ្ជាក់ថាជាមនុស្សស្នាក់នៅក្នុងឃុំ ។ |

## វត្ថុដែលមិនអាចចាត់ការក្នុងឃុំបាន

■ កម្ទេចដុំស៊ីម៉ង់



■ បំពង់ពន្លត់អគ្គិភ័យ



■ ម៉ូតូ (រួមទាំងម៉ូតូខ្នាតតូច)



■ ប្រភេទប្រេង ខ្លាញ់ (ថ្នាំលាបពណ៌, ថ្នាំជូត, ប្រេងសាំង, ប្រេងម៉ាស៊ូតជាដើម)




■ កំរាលបន្ទប់ជប៉ុន Tatami



○ **“វត្ថុដែលមិនអាចចាត់ការក្នុងឃុំបាន” នេះ មិនត្រូវដាក់នៅកន្លែងប្រមូលសំរាម ព្រមទាំងមិនត្រូវយកមក Bika Plant ដែរ ។**

○ **សូមអញ្ជើញទំនាក់ទំនងស្នើសុំចាត់ការចំពោះហាងដែលបានទិញវត្ថុនោះ រឺអាជីវករជំនាញ ។**

**ទំនាក់ទំនង** Kankyoka-haikibutsu-taisakuhan រឺ Bika Plant

**ទូរស័ព្ទ** : 046-285-2111 (លេខផ្ទៃក្នុង 3514)
រឺ 046-281-2258, 046-281-2811

**អាស័យដ្ឋាន** E-mail : kankyo@town.aikawa.kanagawa.jp